រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ: ០៣៦/១៣ អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មីនា ឆ្នាំ២០១៣
## និងទិសដៅការងារ ខែ មេសា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/៣/២០១៣ ដល់ ថ្ងៃទី ៣១/៣/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តន៍តាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្តន៍ "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុង ខែមីនា ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១០ គឺ រាជធានីភ្នំពេញ ខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង, ស្ទឹងត្រែង, រតនគិរី, បាត់ដំបង, បន្ទាយមានជ័យ, ក្រចេះ និង ខេត្តប៉ៃលិន ដែលបានរាយការណ៍ពីការបង្ក្រាបបទល្មើសគ្រឿងញៀននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បានបង្ហាញថា សកម្មភាពចរាចរ ជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀននៅតែបន្តកើតមាន ។ គ្រឿងញៀនទាំងនោះ ភាគច្រើនបាននាំពីតំបន់ត្រីកោណមាស ចូលមកកម្ពុជា តាមច្រកនៃបណ្តាខេត្តនៅព្រំដែនកម្ពុជា-ឡាវ ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបក្នុងខែមីនានេះ មន្ទីរប្រឆាំងគ្រឿងញៀន បង្ក្រាបបានចំបទល្មើសគ្រឿងញៀនធំៗចំនួន ៤ ករណី ព្រមទាំងបានកត់សំគាល់ឃើញទៀតថា នៅទិសខេត្តជាប់ព្រំដែនថៃ សមត្ថកិច្ចបង្ក្រាបបាន ២០ ករណី, ទិសជាប់ព្រំដែនឡាវ បង្ក្រាបបាន ២ ករណី, ទិសជាប់ព្រំដែនវៀតណាម បង្ក្រាបបាន ១១ ករណី និងនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បង្ក្រាបបាន ១៩ ករណី ។

ជាមួយនេះដែរ កងរាជអាវុធហត្ថរាជធានីភ្នំពេញ ក៏បង្ក្រាបបាន ១ ករណីធំ ដោយបានធ្វើការរឹបអូសនូវ ថ្នាំញៀនប្រភេទ



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

គ្រាប់ និង ប្រភេទក្រាមម្សៅ ក្នុងចំនួនគួរកត់សំគាល់ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. អំពីការងារដឹកនាំនៃស្ថាប័នកំពូលរបស់ថ្នាក់ជាតិ

ក្នុងខែមីនានេះ ថ្នាក់ដឹកនាំនៃស្ថាប័នកំពូលរបស់ថ្នាក់ជាតិ បានដឹកនាំធ្វើជាត្រីវិស័យក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

- **រាជរដ្ឋាភិបាល** ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ បានផ្តល់អនុសាសន៍ ៧ ចំណុច ដើម្បីលើកកម្ពស់វិស័យអប់រំ នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា (ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣) ដែលនៅក្នុងចំណុចទី៧ សម្តេចបានលើកឡើងពាក់ព័ន្ធនឹងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍, ការលុបបំបាត់នូវការប្រើប្រាស់គ្រឿងញៀន, ការជួញដូរស្ត្រីនិងកុមារ និងការលុបបំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់ប្រភេទនៅក្នុងសង្គម ។

### ២. ការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានដឹកនាំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ កាលពីថ្ងៃទី១២-១៣ ខែមីនា ឆ្នាំ២០១៣ ។
- បានអនុញ្ញាតឱ្យគណៈប្រតិភូនៃអគ្គស្នងការរងនគរបាលជាតិថៃជួបសំដែងការគួរសម (ថ្ងៃទី១៤/៣/២០១៣) ។
- បានបញ្ជាបខ្ចីមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លី នៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចំនួន ២ លើក គឺនៅថ្ងៃទី២០ និង ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៣) ដែលមានប្រជាពលរដ្ឋតំណាងឱ្យគ្រួសារដែលត្រូវទទួលប័ណ្ណកម្មសិទ្ធិ និងក្រុមយុវជនស្ម័គ្រចិត្តរបស់សម្តេចតេជោ ចូលរួមស្តាប់ប្រមាណ ***១.៣២៦*** នាក់ ។
- បានទៅចូលរួមនិងដឹកនាំកិច្ចប្រជុំ បូកសរុបលទ្ធផលអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ និងលើកទិសដៅការងារឆ្នាំ២០១៣ របស់ខេត្តបន្ទាយមានជ័យ (ថ្ងៃទី២៥/៣/២០១៣) ។
- បានប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ។
- បានប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមសន្និបាតបូកសរុបការងារ ឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ (០៥/៣/២០១៣ នៅសាលមហោស្រពចតុមុខ) ។
- បានណែនាំឱ្យរៀបចំកិច្ចប្រជុំ បូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ នាថ្ងៃទី០៩/៤/២០១៣ នៅខេត្តព្រះវិហារ ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពីខែកុម្ភៈ ឆ្នាំ២០១៣ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

## ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ. និងក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាលមួយចំនួនទៀត ជាអាទិ៍ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំ ថ្ងៃ សប្តាហ៍ និង ខែ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានសកម្មភាពជាក់ស្តែងក្នុងតារាងឧបសម្ព័ន្ធទី១ ។ ដោយឡែក :**

**១- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :**

- បានផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីតុមូលស្តីពី "ការសម្របសម្រួលការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ក្នុងបរិបទគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" នៅវិទ្យុ FM 102 MHz (ថ្ងៃទី០៦/៣/២០១៣) និងស្ថានីយ៍ទូរទស្សន៍ C.T.N និង C.N.C ស្តីពី "ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន" (២៧/៣/២០១៣) ។
- បានស្នើសុំទៅក្រសួងកិច្ចការនារី ដើម្បីបញ្ចូលសារអប់រំពីគ្រឿងញៀនរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងកម្មវិធីជជែកពិភាក្សាពីបញ្ហាយុវជន ដែលបាននិងកំពុងចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា រៀងរាល់ថ្ងៃសុក្រ (សំណើនេះត្រូវបានក្រសួងកិច្ចការនារីឯកភាព) ។
- បានស្នើសុំទៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងព័ត៌មាន, ក្រសួងធម្មការ និងសាសនា ដើម្បីជួយជំរុញឱ្យមានសកម្មភាពអប់រំផ្សព្វផ្សាយស្តីពីបញ្ហាគ្រឿងញៀន ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ពីថ្ងៃទី១៤-១៦ ខែ មេសា ឆ្នាំ២០១៣ ។
- បានផ្តល់កិច្ចសម្ភាសន៍ ស្តីពីលទ្ធផលការងារថ្មីៗដែលសម្រេចបាន និងការគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទា និងការបង្ក្រាបគ្រឿងញៀន នៅប្រទេសកម្ពុជា (០៩/៣/២០១៣) ដល់វិទ្យុអាស៊ីសេរី ។
- បានផ្តល់កិច្ចសម្ភាសន៍ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅកម្ពុជា ឆ្ពោះទៅរកអាស៊ានគ្មានគ្រឿងញៀនឆ្នាំ២០១៥ ដល់អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ក្នុងកម្មវិធី "អរុណសួស្តីកម្ពុជា" ។
- បានផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍បាយ័ន តាមរយៈកម្មវិធីបាយ័នថ្ងៃនេះ ដើម្បីផ្សព្វផ្សាយរបាយការណ៍ ស្តីពីលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២ និងទិសដៅការងារឆ្នាំ២០១៣ របស់ អ.ជ.ប.គ.ញ (២១/៣/២០១៣) ។
- បានបន្តកិច្ចសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន រៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវាត់ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានរៀបចំសំដែងនូវឈុតខ្លីៗជាសារអប់រំពីបញ្ហាគ្រឿងញៀន ។
- បានបន្តកិច្ចសហការជាមួយក្រុមហ៊ុន O range, ក្រុមហ៊ុនភេសជ្ជៈខារ៉ាបាវ, ក្រុមហ៊ុនភេសជ្ជៈកូកាកូឡា, ក្រុមហ៊ុនប៊ី.ខេ.អេ, ទូរទស្សន៍ហង្សមាស, ទូរទស្សន៍ MYTV រៀបចំបញ្ច្រាបខ្លឹមសារអប់រំពី "ផលប៉ះពាល់និង គ្រោះថ្នាក់នៃគ្រឿងញៀន" ទៅកម្មវិធីប្រគំតន្ត្រីឆ្នាំសន្តិភាព, តន្ត្រីខារ៉ាបាវ, តន្ត្រីកូកាកូឡា, តន្ត្រីថៃហ្គ័រ, តន្ត្រី Best of the Best, នៅក្នុងខេត្តគោលដៅ ជាអាទិ៍ ខេត្តកំពត, ខេត្តព្រះសីហនុ, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ពោធិ៍សាត់, ខេត្តសៀមរាប, ខេត្តកំពង់ស្ពឺ, ខេត្តកណ្តាល, ខេត្តកំពង់ចាម ។

- បានគាំទ្រនិងសហការជាមួយក្រុមហ៊ុន "ហ្វូមមេឌា" ក្នុងការបញ្ជ្រាបបញ្ហាគ្រឿងញៀន ទៅក្នុងកម្មវិធី "ប្រគំតន្ត្រីតារាបែតងកម្ពុជាឆ្នាំ២០១៣" និងការ "ប្រគំតន្ត្រីទេសចរណ៍គ្មានគ្រឿងញៀន" នៅក្រុង/ស្រុក ចំនួន ១២ នៃខេត្តបន្ទាយមានជ័យ, បាត់ដំបង, សៀមរាប, កំពង់ធំ, កំពង់ចាម និង ខេត្តស្វាយរៀង ។
- បានចូលរួមក្នុងកម្មវិធីមហោស្រពប្រឡងចម្រៀងសម័យជាតិ ឆ្នាំ២០១៣ (រៀបចំដោយក្រសួងព័ត៌មាន) ដើម្បីជំរុញការបញ្ជ្រាបខ្លឹមសារអប់រំពីគ្រឿងញៀន ។
- បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោល អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការអប់រំពីជំងឺអេដស៍ទាក់ទងនឹងប្រធានបទគ្រឿងញៀន, ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា, សាស្ត្រាចារ្យ និស្សិតពេទ្យ និងបុគ្គលិក នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល ក្រសួងការពារជាតិ, មន្ត្រីរបស់ក្រសួងទំនាក់ទំនង រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច , បុគ្គលិកអង្គការសុភាពបុរសកម្ពុជា ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ និងការងារបណ្តុះបណ្តាលធនធានជនបង្គោល ដែលបានអនុវត្តដោយក្រសួង ស្ថាប័នជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដទៃទៀត ព្រមទាំង អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៤ គឺ ខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តតាកែវ និង ខេត្តកំពង់ស្ពឺ នៅក្នុងខែមីនា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***២៨១.៨១៨*** នាក់ **ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១** ។

## ***ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែមីនា ឆ្នាំ២០១៣ នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ***ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៥៤** ករណី
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១១១** នាក់
- **ចាប់តាមដីកា មាន** ១ ដីកា = ១ នាក់ (ប្រុស) ជនជាតិខ្មែរ

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **១១១** នាក់ ខាងលើ មានប្រុស ៩១ នាក់ ស្រី ២០ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ១០៥ នាក់ (ស្រី ១៦ នាក់) , **វៀតណាម** ៤ នាក់ (ស្រី ៣ នាក់) , កូរ៉េ ១ នាក់ (ស្រី), ចិន ១ នាក់ (ប្រុស) និងចាប់តាមដីកា ១ នាក់ ជនជាតិខ្មែរ (ប្រុស) ត្រូវបានសមត្ថកិច្ច កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីន (WY) ៤.១២១ គ្រាប់, មេតំហ្វេតាមីនក្រាមម្សៅ (Ice) ១៨៤៩,២៥ ក្រាម , កញ្ឆាក្រៀម ៥,០៧ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន :

រថយន្ត ២ គ្រឿង, ម៉ូតូ ១៤ គ្រឿង, ប្រាក់កម្ពុជា ២៦.០១៧.៥០០ រៀល, ប្រាក់អាមេរិក ១.៩៨៦ ដុល្លារ, ប្រាក់ថៃ ១៥០ បាត, ប្រាក់វៀតណាម ៣៨០.០០០.០០០ ដុង ។

### ៩.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសុខាភិបាល ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង ខែមីនា ឆ្នាំ២០១៣ មានដូចខាងក្រោម :

- សារធាតុគីមីគិតជា គីឡូក្រាម ចំនួន ១.៧៨៧.៥០០ Kgs និង ៧.៥០០ លីត្រ
- វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ចំនួន ២០ Kg , ២៦២ g , ១.៧០៥ mg ។

### ៩.៣. ការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តច្បាប់នានា នៅក្នុងខែមីនានេះ សរុបបានចំនួន ៥១ ករណី = ៦១ សំណាក (សំណាក**អវិជ្ជមានសារធាតុញៀន** ៣ សំណាក = ៤ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៥៨ សំណាក = ៩៦ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៣៣ សំណាក = ៥៨ % -មេតំហ្វេតាមីនគ្រាប់ ២២ សំណាក = ៣៥ %

-កញ្ឆា ២ សំណាក = ២ % -ហេរ៉ូអ៊ីន ១ សំណាក = ១ %

**ក្រៅពីការងារកោសលវិច័យ** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានជួបពិភាក្សាការងារជាមួយ នាយកការិយាល័យ UNODC ប្រចាំកម្ពុជា (លោក អូលីវីយេ ឡឺមេ) ដើម្បីស្វែងរកកិច្ចសហប្រតិបត្តិការលើវិស័យថ្មី ដោយបានធ្វើការចាប់អារម្មណ៍ទៅលើសារធាតុគីមី ដែលផលិតចេញពីធម្មជាតិ ដូចជា ម្រះព្រៅភ្នំ ជាដើម ។

**ដោយឡែក :**

- ✓ ធនាគារជាតិនៃកម្ពុជា បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ សម្រាប់រៀបចំក្របខណ្ឌច្បាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងគោលបំណងពិភាក្សាពីការរៀបចំសេចក្តីព្រាងច្បាប់ថ្មី សម្រាប់ការដាក់ទោសការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងការបង្កក ចាប់យក និងរឹបអូសផលនៃបទល្មើស ស្របតាមទម្រង់គតិយុត្តិ និងការអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា និងស្តង់ដារអន្តរជាតិ ។
- ✓ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តប៉ៃលិន និង ខេត្តបន្ទាយមានជ័យ បានធ្វើការកែសម្រួលសមាសភាព តួនាទី ភារកិច្ច ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅ ច្រកទ្វារអន្តរជាតិ "ព្រំ" ខេត្តប៉ៃលិន និង ច្រកទ្វារអន្តរជាតិ "ប៉ោយប៉ែត" ខេត្តបន្ទាយមានជ័យ ។
- ✓ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះសីហនុ បានចេញសេចក្តីសម្រេចស្តីពី ការកែសម្រួលសមាសភាពគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ដើម្បីពង្រឹងយន្តការការងារដឹកនាំកាន់តែមានដំណើរការរលូននិងទទួលនូវប្រសិទ្ធភាពខ្ពស់ ។

(**ការបែងចែកលំអិតនៃការងារកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន មាននៅក្នុងឧបសម្ព័ន្ធ ទី២**)

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជំរកៈ និងសមាហរណកម្ម

### - កម្មវិធីកាត់បន្ថយគ្រោះថ្នាក់

- បានចូលរួមតាមការអញ្ជើញរបស់ប្រធានកម្មវិធីសុខភាពផ្លូវចិត្តនៃក្រសួងសុខាភិបាល ដើម្បីពង្រឹងយន្តការសម្របសម្រួលក្នុងការអនុវត្តកម្មវិធីម្ទុល/សឺរ៉ាំង ជាមួយបណ្តាអង្គការដៃគូនានា កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០១៣ នៅមណ្ឌលសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមកិច្ចប្រជុំស្តីពីគម្រោងមូលនិធិថ្មី ឈ្មោះថា "ការគាំទ្រសហគមន៍សម្រាប់ការកាត់បន្ថយគ្រោះថ្នាក់ពីគ្រឿងញៀន" កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ តាមការអញ្ជើញរបស់អង្គការ ខាន់ណា (KHANA) ។
- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន ៤ រូប ដើម្បីចូលរួមប្រជុំ ស្តីពីផែនការអនុវត្តគម្រោងប្រចាំ ឆ្នាំ ២០១៣ របស់គម្រោង AusAID/HAARP នៅកម្ពុជា កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ។
- បានចូលរួមធ្វើជាសហប្រធានក្រុមការងារនៃការអនុវត្តកម្មវិធីសមាហរណកម្មជំងឺអេដស៍ និងការបង្ការគ្រោះថ្នាក់អំពីគ្រឿងញៀន តាមការអញ្ជើញរបស់អង្គការ FHI360 នាថ្ងៃទី២២ខែមីនាឆ្នាំ២០១៣ នៅសណ្ឋាគារណា-ហ្គាលវើល ។

## ឃ. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

### អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :

- បានរៀបចំកិច្ចប្រជុំពិភាក្សាតុមូលស្តីពី ការសម្របសម្រួលការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ក្នុងបរិបទ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដើម្បីផ្សព្វផ្សាយឱ្យមានការយល់ដឹងបានទូលំទូលាយជាសាធារណៈ អំពីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ និងបញ្ហាគ្រឿងញៀន នាថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ នៅស្ថានីយវិទ្យុ FM 102 MHz [៩] ។
- បានរៀបចំកិច្ចប្រជុំគម្រោង PATROL របស់អង្គការ UNODC និងរៀបចំកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ ស្តីពី "កិច្ចសហប្រតិបត្តិការឆ្លងដែន" កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ។ អង្គការ UNODC បានរៀបចំផែនការសកម្មភាពសម្រាប់ប្រទេស កម្ពុជា និង ថៃ រួចរាល់ហើយសម្រាប់ឆ្នាំ២០១៣ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន និងបទល្មើសនានាឆ្លងកាត់ព្រំដែន ។ សកម្មភាពដំបូងដែលត្រូវអនុវត្តគឺ ការបំពាក់សម្ភារៈថ្មីៗ ជំនួសសម្ភារៈចាស់ៗដែលប្រើការលែងកើត នៅតាមការិយាល័យ BLO ចំនួន ៨ កន្លែងគឺ កម្ពុជា ៤ កន្លែង នៅក្នុងខេត្តកោះកុង ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ និងខាងភាគី ៤ កន្លែងនៅក្នុងខែមេសា ឆ្នាំ២០១៣ និងបន្ទាប់មកនឹងមានការបណ្តុះបណ្តាលរួមគ្នាអំពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងបទល្មើសនានាឆ្លងកាត់ព្រំដែន ។
- បានប្រជុំផ្ទៃក្នុងថ្នាក់ដឹកនាំនាយកដ្ឋានអនុវត្តច្បាប់ កាលពីថ្ងៃទី១៩/៣/២០១៣ ដើម្បីបែងចែកភារកិច្ចជូនថ្នាក់

[៩] កិច្ចពិភាក្សានេះ មានគោលបំណងបង្កើនចំណេះដឹងលើការងារកាត់បន្ថយគ្រោះថ្នាក់ ដល់មន្ត្រីអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព រួមទាំងកងនគរបាលជាតិ ផងដែរ ។

ដឹកនាំនាយកដ្ឋានឱ្យទទួលខុសត្រូវ លើការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ទាំង ១៤ កន្លែង តាមសេចក្តីសម្រេច ស្តីពីការកែសម្រួល សមាសភាព តួនាទី ភារកិច្ច ការិយាល័យ BLO ។

## ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ខែមីនាឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ មានដូចខាងក្រោម :

**ង.១. ការងារក្នុងប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បាននិងកំពុងបំពេញកម្រងសំណួរ របាយការណ៍សម្រាប់ឆ្នាំ២០១២ ស្តីពី The Working of the International Drug Control Treaties and Measyring Progress of the Plan of Action and the Political Declaration ដើម្បីផ្ញើទៅ ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) ។
- ឯកឧត្តម អគ្គលេខាធិការ អ.ជ.ប.គ.ញ បានជួបទទួលនិងពិភាក្សាការងារជាមួយ អគ្គលេខាធិការអចិន្ត្រៃយ៍ផ្នែកសន្តិសុខ និងអនុវត្តច្បាប់ នៃការិយាល័យនាយករដ្ឋមន្ត្រី នៃប្រទេសប្រ៊ុយណេ ពាក់ព័ន្ធនឹងកិច្ចការគ្រឿងញៀន កាលពីថ្ងៃទី០១/៣/២០១៣ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្នុងគោលបំណងជួបពិភាក្សាការងារពាក់ព័ន្ធនឹងដំណើរការកិច្ចប្រជុំពិសេស ថ្នាក់រដ្ឋមន្ត្រី លើកទី២ ស្តីពីបញ្ហាគ្រឿងញៀននិងការផ្លាស់ប្តូរទស្សនកិច្ច ក៏ដូចជាបទពិសោធន៍លើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ពិសេសទស្សនកិច្ចពាក់ព័ន្ធនឹងដំណើរការឆ្ពោះទៅសម្រេចគោលដៅ អាស៊ានគ្មានគ្រឿងញៀន ឆ្នាំ២០១៥ ។
- បានចូលរួមក្នុងកិច្ចប្រជុំ មន្ត្រីជំនាញទទួលបន្ទុកអាស៊ាន សម្រាប់ត្រៀមរៀបចំកិច្ចប្រជុំឧត្តមមន្ត្រីក្រុមប្រឹក្សាសហគមន៍ សង្គម-វប្បធម៌អាស៊ាន លើកទី១៤ និងកិច្ចប្រជុំរដ្ឋមន្ត្រីក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន លើកទី៩ ។

**ង.២. ការងារក្រៅប្រទេស** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមប្រជុំអ្នកគ្រប់គ្រងស៊ើបអង្កេត នៅបណ្ឌិត្យសភាអនុវត្តច្បាប់អន្តរជាតិ (ILEA) នៅទីក្រុងបាងកក ប្រទេសថៃ (១៨-២២/៣/២០១៣) ។

***ការងារផ្សេងៗ :***

***អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :***

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានទៅចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងលើកទិសដៅការងារ ឆ្នាំ២០១៣ របស់ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ ។

# III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តន៍ទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

## ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ស្នើសុំទៅក្រសួងសុខាភិបាល ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភា អ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន និង ស៊ី.អិន.ស៊ី អំពីការព្យាបាលផ្លូវចិត្ត និងកាយសម្បទា ដល់អ្នកញៀនគ្រឿងញៀន ថ្ងៃទី២៤/៤/២០១៣ ។

១.២. ត្រៀមកិច្ចសហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការ សមាគមជាតិ និងអន្តរជាតិ ដើម្បីធ្វើសកម្មភាពអប់រំផ្សព្វផ្សាយស្តីពីបញ្ហាគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំ ប្រពៃណីជាតិខ្មែរ ពីថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០១៣ ។

១.៣. សហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ រៀបចំកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយអប់រំ ពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅវិទ្យាល័យ បាក់ទូក ( ថ្ងៃទី៣១/៣/២០១៣) និងនៅ វិទ្យាល័យ ព្រះយុគន្ធរ ( ថ្ងៃទី២៨/៤/២០១៣) ។

១.៤. បន្តសហការជាមួយបណ្តាក្រុមហ៊ុនឯកជន ដើម្បីរៀបចំបញ្ជ្រាបបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រី នៃកម្មវិធីនានា នៅតាមរាជធានី-ខេត្ត ។

១.៥. បន្តរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវាត់ពានរង្វាន់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្ថានីយទូរ-ទស្សន៍បាយ័ន ដើម្បីបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៦. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៧. បន្តកិច្ចសហការជាមួយកម្មវិធីពេញនិយមតាមបណ្តាស្ថានីយ វិទ្យុ ទូរទស្សន៍ កម្មវិធីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបញ្ជ្រាបចំណេះដឹងពីបញ្ហាគ្រឿងញៀន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការស្រាវជ្រាវអត្តសញ្ញាណជនល្មើស ជនជាតិថៃ ៣ នាក់ ពាក់ព័ន្ធនឹងគ្រឿងញៀន តាមការស្នើសុំរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ។

២.២. សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវ ករណីជនជាតិខ្មែរពីរនាក់ពីបទជួញដូរគ្រឿងញៀនឆ្លងដែន ដែលត្រូវក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ឃាត់ខ្លួនកាលពីថ្ងៃទី០៧/០១/២០១៣ ( ១នាក់) និងនៅថ្ងៃទី១៥/០១/២០១៣ ( ១នាក់) ។

២.៣. សហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីធ្វើការស៊ើបអង្កេតស្រាវជ្រាវ ករណីជនជាតិខ្មែរ ០៨ នាក់ និងថ្នាំញៀនយ៉ាបា ចំនួន ១០.០០០ គ្រាប់ ដែលក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃបានជូនដំណឹងកាលពីថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ។

២.៤. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតលើសេចក្តីព្រាងស្តីពី យន្តការនិងប្រព័ន្ធចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិត្យសារធាតុគីមី ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ត្រៀមចូលរួមក្នុងពិធីសម្ពោធគម្រោង HIV Flagship នៅវត្តទេពពោធិវង្ស ខេត្តសៀមរាប នាថ្ងៃទី១០ខែមេសា ឆ្នាំ២០១៣ តាមការអញ្ជើញរបស់អង្គការ ខាន់ណា ។

៣.២. ចូលរួមក្នុងកិច្ចប្រជុំសភាតំបន់ ស្តីពីគោលនយោបាយគ្រឿងស្រវឹង នៅទីក្រុងហាណូយ ប្រទេសវៀតណាម ថ្ងៃទី ០៦-០៧ ខែមេសា ឆ្នាំ២០១៣ ។

៣.៣. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និងស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៤. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្ជុល/ស៊ីរាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៥. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀនដែលកំពុងសម្រាកព្យាបាល នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៦. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៧. រៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងកម្លាំងឈរជើងនៅតាមតំបន់ព្រំដែន នៃកងយោធពលខេមរភូមិន្ទ ។

៤.២. បន្តរៀបចំវគ្គបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់ តាមប្រព័ន្ធកុំព្យូទ័រ (កម្មវិធី CBT) ។

៤.៣. បន្តសហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា រៀបចំឯកសារបណ្តុះបណ្តាលមន្ត្រីនគរបាលនៅតាមភូមិភាគ ស្តីពីយុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន ។

៤.៤. បន្តកិច្ចសហការជាមួយអង្គការជាដៃគូពាក់ព័ន្ធ លើការងារពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមទៅចូលរួមកិច្ចប្រជុំក្រុមការងារទិន្នន័យព័ត៌មានគ្រឿងញៀន នៅទីក្រុងបាងកក ប្រទេសថៃ ថ្ងៃទី០៣-០៤ ខែមេសា ឆ្នាំ២០១៣ ។

៥.២. សម្របសម្រួលឱ្យមានការផ្លាស់ប្តូរដំណើរទស្សនកិច្ច នៃថ្នាក់ដឹកនាំស្ថាប័នត្រួតពិនិត្យគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។

៥.៣. ត្រៀមរៀបចំដំណើរទស្សនកិច្ច សម្រាប់គណៈប្រតិភូ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅទស្សនកិច្ចនៅ ខេត្តយូណាន ប្រទេសចិន ។

៥.៤. ចាត់បញ្ជូនមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ២០ រូប ទៅទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្នុងស៊ើបអង្កេត បទល្មើសគ្រឿងញៀន និងការវិភាគគ្រឿងញៀន នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ពីថ្ងៃទី០៧ ដល់ ថ្ងៃទី១១

ខែមេសា ឆ្នាំ២០១៣ ។

៥.៥. ត្រៀមទៅចូលរួមកិច្ចប្រជុំក្រុមការងារ សម្រាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (APICC) ដែលនឹងប្រព្រឹត្តនៅថ្ងៃទី០៣-០៤ ខែមេសា ឆ្នាំ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.៦. ត្រៀមទៅចូលរួមកិច្ចប្រជុំសកាតំបន់ ស្តីពីគោលនយោបាយគ្រឿងស្រវឹង នៅទីក្រុងហាណូយ ប្រទេសវៀតណាម (ថ្ងៃទី០៦-០៧/៤/២០១៣) ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- ត្រៀមរៀបចំកិច្ចប្រជុំ បូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ នៅខេត្តព្រះវិហារ ។
- បន្តការរៀបចំវគ្គបណ្តុះបណ្តាល ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ច្បាប់ថ្មី) ។
- បន្តសហការជាមួយ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ដំណើរការរៀបចំបញ្ចូល ផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន ក្នុងការសិក្សា ការអង្កេតរកអត្រា ប្រេវ៉ាឡង់មេរោគអេដស៍ និងឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ។
- បន្តការកែសម្រួលអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក យូ_ស៊ីនឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ